# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជានៅព្រះសហគមន៍សន្តហ្វ្រង់ស្វ័រសាវីយេ
# គខនយ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៩

## ព្រះសហគមន៍ជាតំណាងព្រះយេស៊ូ

**អត្ថបទទី១៖ ពង្សាវតារក្សត្រទី២ ៥,១៤-១៧**

លោកណាម៉ាន់ក៏ចុះទៅក្នុងទន្លេយ័រដាន់ ហើយមុជក្នុងទឹកចំនួនប្រាំពីរដង តាមពាក្យដែលអ្នកជំនិតរបស់ព្រះជាម្ចាស់បានប្រាប់ ស្រាប់តែសាច់របស់លោកឡើងស្អាត ដូចសាច់កូនក្មេង លោកក៏ជាស្អាតបរិសុទ្ធ។ ២ពង្ស ៥,១៤

**អត្ថបទទី២៖ ធីម៉ូថេទី២ ២,៨-១៣**

ខ្ញុំរងទុក្ខលំបាកព្រោះតែដំណឹងល្អនេះ រហូតដល់ត្រូវគេចាប់ចង ដូចជាបានប្រព្រឹត្តអំពើអាក្រក់ រីឯព្រះបន្ទូលរបស់ព្រះជាម្ចាស់វិញ គេពុំអាចចាប់ចងបានឡើយ។ ២ធម ២,៩

**ដំណឹងល្អ៖ លូកា ១៧,១១-១៩**

ព្រះយេស៊ូទតមើលគេ ហើយមានព្រះបន្ទូលថា៖ «ចូរអ្នករាល់គ្នាទៅបង្ហាញខ្លួនឲ្យពួកបូជាចារ្យឃើញចុះ»។ លក ១៧,១៤

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងស្តាប់អត្ថបទអំពីមនុស្សដែលមានជំងឺឃ្លង់ បើយើងប៉ះពាល់អ្នកជំងឺនេះយើងនឹងឆ្លងជំងឺពីគេដែរ ហើយមេរោគនេះវាស៊ីកោសិកាយើងបន្តិចម្តងៗរហូតដល់យើងស្លាប់។ ព្រះយេស៊ូបានជួបជាមួយមនុស្សដែលមានជំងឺឃ្លង់ដប់នាក់ នៅសម័យហ្នឹងអ្នកជំងឺឃ្លង់មិនហ៊ាននៅជិតប្រជាជនធម្មតាទេខ្លាចឆ្លងដល់គេ។ អ្នកជំងឺឃ្លង់ទាំងនោះបានសុំ "**ឱព្រះយេស៊ូអើយ! សូមជួយព្យាបាលខ្ញុំផង**" នៅពេលនោះព្រះយេស៊ូមានព្រះបន្ទូលថា "**ចូរអ្នករាល់គ្នាទៅបង្ហាញខ្លួនឲ្យពួកបូជាចារ្យឃើញចុះ៖ អ្នកបានជាស្អាតបរិសុទ្ធគ្រប់ៗគ្នាហើយ**"។ ក្នុងចំណោមដប់នាក់ មានតែម្នាក់ដែលបានត្រឡប់មកអរព្រះគុណព្រះយេស៊ូវិញ ដោយបានកោតសរសើរសិរីរុងរឿងរបស់ព្រះជាម្ចាស់ ដោយយល់ថាគាត់បានព្យាបាលទាំងរូបកាយទាំងវិញ្ញាណ។ សូមចាប់អារម្មណ៍របៀបព្រះយេស៊ូ ព្រះអង្គទតមើលអ្នកជំងឺនិងព្យាបាលឲ្យគេជាសះស្បើយ អ្នកពិការដើរបាន អ្នកខ្វាក់មើលឃើញ អ្នកឃ្លង់បានស្អាតបរិសុទ្ធ អ្នកដែលឃ្លានព្រះអង្គឲ្យគេឆ្អែតបរិបូរណ៍។ ព្រះយេស៊ូមិនរើសមនុស្ស អ្នកណាមកដល់ព្រះអង្គទទួលស្វាគមន៍និងព្យាបាលគេ ព្រះសហគមន៍ជាតំណាងរបស់ព្រះយេស៊ូនៅទីនេះ ឲ្យយើងទទួលស្វាគមន៍អស់អ្នកដែលមករកព្រះអង្គ។ ព្រះយេស៊ូមិនរើសអ្នកណាទេ អ្នកដែលមកព្រះអង្គទទួលស្វាគមន៍គេនិងឆ្លើយតបសេចក្តីត្រូវការរបស់គេ។ នេះជាតួនាទីរបស់ព្រះសហគមន៍យើងក្នុងការប្រកាសដំណឹងល្អ មុននិយាយអំពីព្រះ

បន្ទូលដំណឹងល្អយើងត្រូវតែធ្វើដូចព្រះយេស៊ូ មើលសេចក្តីត្រូវការរបស់បងប្អូន **តើយើងឆ្លើយតបដូចម្តេចដល់សេចក្តីត្រូវការទាំងនោះ?** អ្វីៗទាំងអស់ដែលយើងមើលឃើញនៅក្នុងភូមិរបស់យើង។ សូមចាប់អារម្មណ៍នៅពេលព្រះយេស៊ូបានព្យាបាលដប់នាក់មានតែម្នាក់ដែលវិលមករកព្រះអង្គវិញ។ ព្រះយេស៊ូបានសួរគាត់ថា "**តើប្រាំបួននាក់ទៀតមិនបានស្អាតបរិសុទ្ធដូចអ្នកទេឬ?**" ព្រះយេស៊ូមានព្រះបន្ទូលសំខាន់ណាស់សម្រាប់យើងថ្ងៃនេះ "**ចូរក្រោកឡើងអញ្ជើញទៅចុះ ជំនឿរបស់អ្នកបានសង្គ្រោះអ្នកហើយ**" ដូច្នេះគាត់មិនតែជាសះស្បើយរូបកាយរបស់គាត់ ព្រះយេស៊ូបានព្យាបាលដួងចិត្តនិងវិញ្ញាណរបស់គាត់ថែមទៀត។

យើងប្រកាសដំណឹងល្អដោយនឹកឃើញសេចក្តីត្រូវការរបស់បងប្អូនឯទៀតៗ យើងសាបព្រោះច្រើនប៉ុន្តែមានតែម្នាក់ដែលយល់ថាព្រះជាម្ចាស់ជាជីវិតថ្មីរបស់គេ។ ព្រះយេស៊ូមិនតែព្យាបាលរូបកាយ ព្រះអង្គចង់ព្យាបាលរបួសដែលមាននៅក្នុងដួងចិត្តរបស់យើង ហើយអ្វីដែលស្ថិតស្ថេរអស់កល្បជានិច្ចគឺជំនឿដែលយើងជឿលើព្រះជាម្ចាស់។ មុនសម័យប៉ូលពត ព្រះសហគមន៍យើងមានសមត្ថភាពច្រើន មានការរីកចម្រើនខ្លាំង ប៉ុន្តែនៅក្នុងសម័យប៉ូលពតណែនាំឲ្យបូជាចារ្យ បងប្រុសបងស្រី ខ្លះស្លាប់ខ្លះវិលទៅប្រទេសគេវិញ និងបំផ្លាញព្រះសហគមន៍យើងទាំងអស់។ អាគារក៏អស់ អ្នកដឹកនាំព្រះសហគមន៍ក៏អស់ គ្រីស្តបរិស័ទក៏អស់ ប៉ុន្តែនៅសល់ជំនឿដោយសារបងប្អូនដែលជាគ្រីស្តបរិស័ទគេជឿថាព្រះជាម្ចាស់ស្រឡាញ់គេ។ អត្ថបទទីពីរ "**ប្រសិនបើយើងរួមស្លាប់ជាមួយព្រះគ្រីស្ត យើងក៏រួមរស់ជាមួយព្រះអង្គ ប្រសិនបើយើងស៊ូទ្រាំយើងនឹងគ្រងរាជ្យរួមជាមួយព្រះអង្គ បើយើងបដិសេធមិនទទួលស្គាល់ព្រះអង្គ ព្រះអង្គក៏នឹងបដិសេធមិនទទួលស្គាល់យើងនៅស្ថានបរមសុខដែរ**"។

នៅប្រទេសជប៉ុន ៣០០ឆ្នាំមុនមានសន្តប្រាំងស្វ័រសាវីយេដែលបានទៅប្រកាសដំណឹងល្អពេលនោះមានតែអ្នកដែលគោរពសាសនាដទៃ នៅពេលគេស្តាប់ប្រាំងស្វ័រសាវីយេប្រកាសដំណឹងល្អមានច្រើនគេបានចាប់អារម្មណ៍ មានច្រើនគេបានទទួលអគ្គសញ្ញាជ្រមុជទឹក។ ក្រោយមករដ្ឋអំណាចអន់ចិត្តនិងសាសនាយើង ហាមប្រជាជនជប៉ុនទាំងអស់មិនឲ្យកាន់សាសនាយើងបណ្តេញសាសនទូតទាំងអស់នៅសល់តែគ្រីស្តបរិស័ទជនជាតិជប៉ុន។ នៅពេលនោះ គេណែនាំឲ្យប្រជាជនជប៉ុនបដិសេធនឹងជំនឿផ្ទាល់ខ្លួន ដូច្នេះគេយករូបព្រះយេស៊ូ រូបព្រះនាងម៉ារី ឈើឆ្កាង មកដាក់លើដីហើយឲ្យប្រជាជនដើរជាន់ ប្រសិនបើអ្នកដែលព្រមជាន់នៅមានជីវិតតែបើមិនព្រមជាន់គេនឹងសម្លាប់។ មានមួយចំនួនដែលព្រមជាន់ដោយបដិសេធជាមួយព្រះយេស៊ូ និងមានមួយចំនួនគេមានជំនឿលើព្រះជាម្ចាស់ដូច្នេះរដ្ឋអំណាចបានសម្លាប់ពួកគេ។ នៅពេលគេជិតស្លាប់ គេបានច្រៀងកោតសរសើរព្រះជាម្ចាស់ ដោយសារគេយល់ថាទោះបីគេស្លាប់លើផែនដី

នេះ គេនឹងមានជីវិតនៅស្ថានបរមសុខជាមួយព្រះជាម្ចាស់។ ហើយមានមួយចំនួនទៀត គេបានរត់ចូលទៅក្នុងព្រៃដើម្បីគេចពីរដ្ឋអំណាច ដោយគេបានបន្តអធិដ្ឋាននិងបន្តជ្រមុជទឹកឲ្យកូនចៅគេតៗគ្នា ដោយឥតមានបូជាចារ្យ ឥតមានបងប្រុសបងស្រី ឥតមានគ្រូអប់រំជំនឿ ប៉ុន្តែគេចាំធម៌ឱព្រះបិតា ធម៌បពិត្រព្រះនាងម៉ារី គេចាំពិធីជ្រមុជទឹក...។ នៅក្នុងព្រៃហ្នឹង គេបានអធិដ្ឋាន គេបានធ្វើពិធីជ្រមុជទឹកឲ្យគ្នា អស់រយៈពេល២៥០ឆ្នាំ ក្រោយមកមានសាសនទូតម្នាក់បានរកឃើញគ្រីស្តបរិស័ទជនជាតិជប៉ុនទាំងអស់នោះ១០,០០០នាក់។ នេះជាកូនចៅរបស់គ្រីស្តបរិស័ទ ដែលបានរត់ចូលព្រៃដើម្បីគេចពីរដ្ឋអំណាច២៥០ឆ្នាំមុន ដោយបានបន្តថែរក្សាជំនឿ។ យើងដឹងថាជំនឿស្ថិតស្ថេរទោះបីឥតមានអាគារថ្វាយអភិបូជា ឥតមានលោកបូជាចារ្យដើម្បីណែនាំ គេមានជំនឿដែលគេបានទទួលនិងថែរក្សាជំនឿនេះនៅក្នុងសេចក្តីស្រឡាញ់។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទ យើងត្រូវការអប់រំបងប្អូនដែលនៅជុំវិញយើងឲ្យគេយល់ថា យើងប្រកាសដំណឹងល្អដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់បងប្អូនឯទៀតៗ។ ព្រះយេស៊ូមិនចង់ឲ្យយើងមានសេចក្តីសុខតែនៅក្នុងសង្គម ព្រះអង្គចង់ឲ្យយើងមានសេចក្តីសុខនៅក្នុងចិត្តដោយថែរក្សាជំនឿរបស់យើងលើព្រះជាម្ចាស់។

យើងអធិដ្ឋាន ដើម្បីឲ្យយើងមានជំនឿរឹងមាំ ឲ្យយើងចេះប្រកាសដំណឹងល្អដើម្បីឲ្យបងប្អូនមានសេចក្តីសុខនៅក្នុងសង្គម និងជាពិសេសសេចក្តីសុខនៅក្នុងចិត្តរបស់បងប្អូន។ អាម៉ែន៕